

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ិចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីសិក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# កថាវត្ថុ តតិយភាគ
# ៨៦

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០៩

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤


សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# អភិធម្មបិដក

## កថាវត្ថុ តតិយភាគ

៨៦

ព. ស. ២៥០៩

# អភិធម្មបិដកេ

## កថាវត្ថុស្ស តតិយោ ភាគោ

## តិស្សោបិ អនុសយកថា

---

(១) អនុសយា អព្យាកតាតិ ។ អាមន្តា ។ វិបាកាព្យាកតា កិរិយាព្យាកតា រូបំ និព្វានំ ចក្ខាយតនំ ។បេ។ ផោដ្ឋព្វាយតនន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(២) កាមរាគានុសយោ អព្យាកតោតិ ។ អាមន្តា ។ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណំ អកុសលន្តិ ។ អាមន្តា ។ កាមរាគានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣) បដិឃានុសយោ អព្យាកតោតិ ។ អាមន្តា ។ បដិឃំ បដិឃបរិយុដ្ឋានំ បដិឃសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បដិឃំ បដិឃបរិយុដ្ឋានំ បដិឃសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ បដិឃានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

# អភិធម្មបិដក

## កថាវត្ថុ តតិយភាគ

## តិស្សោបិ អនុសយកថា

---

(១) សក: អនុស័យ ជាអព្យាក្រឹត ឬ ។ បរ: អើ ។ វិបាកនិងអព្យាក្រឹត កិរិយានិងអព្យាក្រឹត រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ (ជាអព្យាក្រឹត) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(២) កាមរាគានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ ជាអកុសលឬ ។ អើ ។ កាមរាគានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣) បដិឃានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ បដិឃៈ បដិឃបរិយុដ្ឋានៈ បដិឃសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិឃៈ បដិឃបរិយុដ្ឋានៈ បដិឃសញ្ញោជនៈ ជាអកុសលដែរឬ ។ អើ ។ បដិឃានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦) មានានុសយោ អព្យាកតោតិ ។ អាមន្តា ។ មានោ មានបរិយុដ្ឋានំ មានសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ មានោ មានបរិយុដ្ឋានំ មានសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ មានានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៧) ទិដ្ឋានុសយោ អព្យាកតោតិ ។ អាមន្តា ។ ទិដ្ឋិ ទិដ្ឋោឃោ ទិដ្ឋិយោគោ ទិដ្ឋិបរិយុដ្ឋានំ ទិដ្ឋិសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ទិដ្ឋិ ទិដ្ឋោឃោ ទិដ្ឋិយោគោ ទិដ្ឋិបរិយុដ្ឋានំ ទិដ្ឋិសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ ទិដ្ឋានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨) វិចិកិច្ឆានុសយោ អព្យាកតោតិ ។ អាមន្តា ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណំ អកុសលន្តិ ។ អាមន្តា ។ វិចិកិច្ឆានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤) មានានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ មានៈ មានបរិយុដ្ឋានៈ មានសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មានៈ មានបរិយុដ្ឋានៈ មានសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ មានានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥) ទិដ្ឋានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ ទិដ្ឋិ ទិដ្ឋោឃៈ ទិដ្ឋិយោគៈ ទិដ្ឋិបរិយុដ្ឋានៈ ទិដ្ឋិសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទិដ្ឋិ ទិដ្ឋោឃៈ ទិដ្ឋិយោគៈ ទិដ្ឋិបរិយុដ្ឋានៈ ទិដ្ឋិសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ ទិដ្ឋានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦) វិចិកិច្ឆានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានៈ វិចិកិច្ឆាសញ្ញោជនៈ វិចិកិច្ឆានីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានៈ វិចិកិច្ឆាសញ្ញោជនៈ វិចិកិច្ឆានីវរណៈ ជាអកុសលឬ ។ អើ ។ វិចិកិច្ឆានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧) ភវរាគានុសយោ អព្យាកតោតិ ។ អាមន្តា ។ ភវរាគោ ភវរាគបរិយុដ្ឋានំ ភវរាគសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ភវរាគោ ភវរាគបរិយុដ្ឋានំ ភវរាគសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ ភវរាគានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨) អវិជ្ជានុសយោ អព្យាកតោតិ ។ អាមន្តា ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ អកុសលន្តិ ។ អាមន្តា ។ អវិជ្ជានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩) ន វត្តព្វំ អនុសយា អព្យាកតាតិ ។ អាមន្តា ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សានុសយោតិ វត្តព្វោតិ ។ អាមន្តា ។

តិស្សោបិ អនុសយកថា

(៧) ភវរាគានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ ភវរាគៈ ភវរាគបរិយុដ្ឋានៈ ភវរាគសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ភវរាគៈ ភវរាគបរិយុដ្ឋានៈ ភវរាគសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ ភវរាគានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨) អវិជ្ជានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋានៈ អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋានៈ អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ ជាអកុសលឬ ។ អើ ។ អវិជ្ជានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩) បុគ្គលមិនគួរពោលថា អនុស័យ ជាអព្យាក្រឹតទេ ឬ ។ អើ ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយអនុស័យឬ ។ អើ ។

កុសលាកុសលា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អនុសយា អព្យាកតាតិ ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សរាគោតិ វត្តព្វោតិ ។ អាមន្តា ។ កុសលាកុសលា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ រាគោ អព្យាកតោតិ ។

(១០) អនុសយា អហេតុកាតិ ។ អាមន្តា ។ រូបំ និព្វានំ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមរាគានុសយោ អហេតុកោតិ ។ អាមន្តា ។ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ ។ បេ ។ កាមច្ឆន្ទនីវរណំ អហេតុកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណំ សហេតុកន្តិ ។ អាមន្តា ។ កាមរាគានុសយោ សហេតុកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បដិឃានុសយោ ។ បេ ។ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ ។ បេ ។

កុសលធម៌ និងអកុសលធម៌ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អនុស័យ ជាអព្យាក្រឹត ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គល គួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ កុសលធម៌និងអកុសលធម៌ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ រាគៈ ជាអព្យាក្រឹត ។

(១០) អនុស័យ មិនមានហេតុទេឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ (មិនមានហេតុ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមរាគានុស័យ មិនមានហេតុឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ កាមរាគសញ្ញោជនៈ ។ ។ បេ ។ កាមច្ឆន្ទនីវរណៈ មិនមានហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ ប្រកបដោយហេតុឬ ។ អើ ។ កាមរាគានុស័យ ប្រកបដោយហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បដិឃានុស័យ ។ បេ ។ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ ។ បេ ។

## តិស្សោបិ អនុសយកថា

អវិជ្ជានុសយោ អហេតុកោតិ ។ អាមន្តា ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ អហេតុកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជា អវិជ្ជោឃោ ។ បេ ។ អវិជ្ជានីវរណំ សហេតុកន្តិ ។ អាមន្តា ។ អវិជ្ជានុសយោ សហេតុកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១១) ន វត្តព្វំ អនុសយា អហេតុកាតិ ។ អាមន្តា ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សានុសយោតិ វត្តព្វោតិ ។ អាមន្តា ។ អនុសយា តេន ហេតុនា សហេតុកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អនុសយា អហេតុកាតិ ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សរាគោតិ វត្តព្វោតិ ។ អាមន្តា ។ រាគោ តេន ហេតុនា សហេតុកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ រាគោ អហេតុកោតិ ។

(១២) អនុសយា ចិត្តវិប្បយុត្តាតិ ។ អាមន្តា ។ រូបំ និព្វានំ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនន្តិ ។

តិស្សេបិ អនុសយកថា

អវិជ្ជានុស័យ មិនមានហេតុឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋានៈ អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ មិនមានហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជា អវិជ្ជោឃៈ ។ បេ ។ អវិជ្ជានីវរណៈ ប្រកបដោយហេតុឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១១) បុគ្គលមិនគួរពោលថា អនុស័យមិនមានហេតុទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ អនុស័យប្រកបដោយហេតុ ដោយហេតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អនុស័យ មិនមានហេតុ ។ បុថុជ្ជន កាលបើចិត្ត ជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គល គួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ រាគៈ ប្រកបដោយហេតុ ដោយហេតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ រាគៈ មិនមានហេតុទេ ។

(១២) អនុស័យ ប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ (ប្រាសចាកចិត្ត) ដែរឬ ។

ន ហេវំ វត្តព្វេ ។បេ។ កាមរាគានុសយោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណំ ចិត្តវិប្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ កាមរាគោ កាមរាគបរិយុដ្ឋានំ ។បេ។ កាមច្ឆន្ទនីវរណំ ចិត្តសម្បយុត្តន្តិ ។ អាមន្តា ។ កាមរាគានុសយោ ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៣) កាមរាគានុសយោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កតមក្ខន្ធបរិយាបន្នោតិ ។ សង្ខារក្ខន្ធបរិយាបន្នោតិ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៤) កាមរាគានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កាមរាគោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមរាគានុស័យ ប្រាសចាកចិត្តដែរឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ ប្រកបដោយចិត្តឬ ។ អើ ។ កាមរាគានុស័យ ប្រកបដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៣) កាមរាគានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ កាមរាគានុស័យ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាក្ខន្ធ សញ្ញាក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៤) កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

កាមរាគោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កាមរាគានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៨) កាមរាគានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តវិប្បយុត្តោ កាមរាគោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តសម្បយុត្តោតិ ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៩) បដិឃានុសយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ អវិជ្ជា អវិជ្ជាយោ អវិជ្ជាយោគោ ។ បេ ។ អវិជ្ជានីវរណំ ចិត្តវិប្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

តិស្សោបិ អនុសយកថា

កាមរាគៈ ដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អើ ។ កាមរាគានុស័យ ដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៥) កាមរាគានុស័យ ដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្ត កាមរាគៈ ដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ខ្លះប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៦) បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ ។ បេ ។ អវិជ្ជានីវរណៈ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អវិជ្ជា អវិជ្ជាយោ អវិជ្ជាយោគោ ។ បេ ។ អវិជ្ជានី-វរណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ អវិជ្ជានុសយោ ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជានុសយោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កតមក្ខន្ធបរិយាបន្នោតិ ។ សង្ខារក្ខន្ធបរិយាបន្នោតិ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជានុសយោ សង្ខារក្ខន្ធ-បរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ អវិជ្ជា សង្ខារក្ខន្ធបរិយាបន្នា ចិត្តវិប្បយុត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជា សង្ខារក្ខន្ធបរិយាបន្នា ចិត្ត-សម្បយុត្តាតិ ។ អាមន្តា ។ អវិជ្ជានុសយោ សង្ខារ-ក្ខន្ធបរិយាបន្នោ ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្ត-វិប្បយុត្តោ អវិជ្ជា សង្ខារក្ខន្ធបរិយាបន្នា ចិត្តសម្ប-យុត្តាតិ ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេសោ

អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ ។ បេ ។ អវិជ្ជានីវរណៈ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជានុស័យ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អើ ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ចុះអវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត

## តិស្សេបិ អនុសយកថា

ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៧) ន វត្តព្វំ អនុសយា ចិត្តវិប្បយុត្តាតិ ។ អាមន្តា ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សានុសយោតិ វត្តព្វោតិ ។ អាមន្តា ។ អនុសយា តេន ចិត្តេន សម្បយុត្តាតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ អនុសយា ចិត្តវិប្បយុត្តាតិ ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សរាគោតិ វត្តព្វោតិ ។ អាមន្តា ។ រាគោ តេន ចិត្តេន សម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ រាគោ ចិត្តវិប្បយុត្តោតិ ។

តិស្សេបិ អនុសយកថា ។

តិស្សោបិ អនុសយកថា

ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៧) បុគ្គលមិនគួរពោលថា អនុស័យ ប្រាសចាកចិត្តទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ អនុស័យ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អនុស័យ ប្រាសចាកចិត្ត ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា ប្រកបដោយរាគៈដែរឬ ។ អើ ។ រាគៈ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ រាគៈ ប្រាសចាកចិត្ត ។

ចប់ តិស្សោបិ អនុសយកថា ។

# ញាណកថា

(១៨) អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ ន វត្តព្វំ ញាណីតិ ។ អាមន្តា ។ កាមេ វិគតេ ន វត្តព្វំ វីតកាមោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ ន វត្តព្វំ ញាណីតិ ។ អាមន្តា ។ ទោសេ វិគតេ ។បេ។ មោហេ វិគតេ ។បេ។ កិលេសេ វិគតេ ន វត្តព្វំ និក្កិលេសោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៩) កាមេ វិគតេ វត្តព្វំ វីតកាមោតិ ។ អាមន្តា ។ អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ វត្តព្វំ ញាណីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទោសេ វិគតេ ។បេ។ មោហេ វិគតេ ។បេ។ កិលេសេ វិគតេ វត្តព្វំ និក្កិលេសោតិ ។ អាមន្តា ។

# ញាណកថា

(១៨) កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គល មិនគួរនិយាយថា មានញាណទេឬ ។ អើ ។ កាលបើរាគៈ ប្រាសចេញហើយ បុគ្គល មិនគួរនិយាយថា មានរាគៈទៅប្រាសហើយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលមិនគួរនិយាយថា មានញាណទេឬ ។ អើ ។ កាលបើទោសៈ ប្រាសចេញហើយ ។ បេ ។ កាលបើមោហៈ ប្រាសចេញហើយ ។ បេ ។ កាលបើកិលេស ប្រាសចេញហើយ បុគ្គលមិនគួរនិយាយថា មិនមានកិលេសទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៩) កាលបើរាគៈ ប្រាសចេញហើយ បុគ្គលគួរនិយាយថា មានរាគៈទៅប្រាសហើយឬ ។ អើ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបើទោសៈ ប្រាសចេញហើយ ។ បេ ។ កាលបើមោហៈ ប្រាសចេញហើយ ។ បេ ។ កាលបើកិលេស ប្រាសចេញហើយ បុគ្គលគួរនិយាយថា មិនមានកិលេសទេឬ ។ អើ ។

អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ វត្តព្វំ ញាណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ វត្តព្វំ ញាណីតិ ។ អាមន្តា ។ អតីតេន ញាណេន ញាណី និរុទ្ធេន វិគតេន បដិប្បស្សទ្ធេន ញាណេន ញាណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ញាណកថា ។

# ញាណំ ចិត្តវិប្បយុត្តន្តិកថា

(២០) ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ រូបំ និព្វានំ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ ចិត្តសម្បយុត្តោតិ ។ អាមន្តា ។ ញាណំ ចិត្តសម្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អើ ។ បុគ្គលមានញាណ ដោយញាណ ជាអតីត មានញាណដោយញាណ ដែលរលត់ហើយ ប្រាសចេញហើយ ស្ងប់រម្ងាប់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ ញាណកថា ។

## ញាណ ចិត្តវិប្បយុត្តិកថា

(២០) ញាណ ប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ ( ប្រាសចាកចិត្ត ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណ ប្រាសចាកចិត្តដែរឬ ។ អើ ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គៈ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គៈ ប្រកបដោយចិត្តឬ ។ អើ ។ ញាណប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២១) ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ កតមក្ខន្ធបរិយាបន្នន្តិ ។ សង្ខារក្ខន្ធបរិយាបន្នន្តិ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា ចិត្តវិប្បយុត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា ចិត្តសម្បយុត្តាតិ ។ អាមន្តា ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ ចិត្តសម្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ ចិត្តវិប្បយុត្តំ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា ចិត្តសម្បយុត្តាតិ ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២១) ញាណ ប្រាសចាកចិត្តឬ ។ អើ ។ ញាណ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អើ ។ បញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អើ ។ ញាណដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តហើយ ចុះបញ្ញាដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២២) ន វត្តព្វំ ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ អរហា ចក្ខុវិញ្ញាណសមង្គី ញាណីតិ វត្តព្វោតិ ។ អាមន្តា ។ ញាណំ តេន ចិត្តេន សម្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ ញាណំ ចិត្តវិប្បយុត្តន្តិ ។ អរហា ចក្ខុវិញ្ញាណសមង្គី បញ្ញវាតិ វត្តព្វោតិ ។ អាមន្តា ។ បញ្ញា តេន ចិត្តេន សម្បយុត្តាតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ បញ្ញា ចិត្តវិប្បយុត្តាតិ ។

ញាណំ ចិត្តវិប្បយុត្តន្តិកថា ។

## ឥទំ ទុក្ខន្តិកថា

(២៣) ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ អយំ សមុទយោតិ វាចំ ភាសតោ អយំ សមុទយោតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ អយំ និរោធោតិ វាចំ ភាសតោ អយំ និរោធោតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(២២) បុគ្គលមិនគួរនិយាយថា ញាណ ប្រាសចាកចិត្តទេឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយចក្ខុវិញ្ញាណ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អើ ។ ញាណ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ញាណ ប្រាសចាកចិត្ត ។ ព្រះអរហន្ត ប្រកបដោយចក្ខុវិញ្ញាណ បុគ្គលគួរនិយាយថា មានបញ្ញាដែរឬ ។ អើ ។ បញ្ញា ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ បញ្ញា ប្រាសចាកចិត្ត ។

ចប់ ញាណចិត្តវិប្បយុត្តន្តិកថា ។

## ឥទំ ទុក្ខន្តិកថា

(២៣) បុគ្គលកាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយវាចាថា នេះជាហេតុនាំឲ្យកើតទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយវាចាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយវាចាថា នេះជាទីរលត់ទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទីរលត់ទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ឥទំ ទុក្ខន្តិ វចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ អយំ មគ្គោតិ វចំ ភាសតោ អយំ មគ្គោតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៨) អយំ សមុទយោតិ វចំ ភាសតោ ន ច អយំ សមុទយោតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អយំ និរោធោតិ ។ បេ ។ អយំ មគ្គោតិ វចំ ភាសតោ ន ច អយំ មគ្គោតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៩) ឥទំ ទុក្ខន្តិ វចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ រូបំ អនិច្ចន្តិ វចំ ភាសតោ រូបំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទំ ទុក្ខន្តិ វចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។

បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាមគ្គ ញាណប្រព្រឹត្តទៅថា នេះជាមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៨) បុគ្គលកាលនិយាយពាក្យថា នេះជាហេតុនាំឲ្យកើតទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទីរលត់ទុក្ខ ។ បេ ។ នេះជាមគ្គ តែញាណ មិនប្រព្រឹត្តទៅថា នេះជាមគ្គឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៩) បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា រូបមិនទៀង ញាណ ប្រព្រឹត្តទៅថា រូបមិនទៀងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។

វេទនា ។ បេ ។ សញ្ញា សង្ខារា ។ បេ ។ វិញ្ញាណំ អនិច្ចន្តិ យំ ភាសតោ វិញ្ញាណំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៦) ឥទំ ទុក្ខន្តិ យំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ រូបំ អនត្តាតិ យំ ភាសតោ រូបំ អនត្តាតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទំ ទុក្ខន្តិ យំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ អនត្តាតិ យំ ភាសតោ វិញ្ញាណំ អនត្តាតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៧) រូបំ អនិច្ចន្តិ យំ ភាសតោ ន ច រូបំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ យំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ វេទនា ។បេ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ អនិច្ចន្តិ

បុគ្គលកាលនិយាយកថាថា វេទនា ។ បេ ។ សញ្ញា សង្ខារ ។ បេ ។ វិញ្ញាណ មិនទៀង ញាណ ប្រព្រឹត្តទៅថា វិញ្ញាណ មិនទៀងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៦) បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា រូបមិនមែនជារបស់ខ្លួន ញាណ ប្រព្រឹត្តទៅថា រូបមិនមែនជារបស់ខ្លួនដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ មិនមែនជារបស់ខ្លួន ញាណ ប្រព្រឹត្តទៅថា វិញ្ញាណ មិនមែនជារបស់ខ្លួនដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៧) បុគ្គលកាលនិយាយកថាថា រូបមិនទៀង តែញាណ មិនប្រព្រឹត្តទៅថា រូបមិនទៀងទេឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយកថាថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ មិនទៀង

វាចំ ភាសតោ ន ច វិញ្ញាណំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ អនត្តាតិ វាចំ ភាសតោ ន ច រូបំ អនត្តាតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ អនត្តាតិ វាចំ ភាសតោ ន ច វិញ្ញាណំ អនត្តាតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨] ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥតិ ច ទន្តិ ច ទុតិ ច ខន្តិ ច ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ឥទំ ទុក្ខន្តិកថា ។

តែញាណ មិនប្រព្រឹត្តទៅថា វិញ្ញាណមិនទៀងទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា រូបមិនមែនជារបស់ខ្លួន តែញាណ មិនប្រព្រឹត្តទៅថា រូបមិនមែនជារបស់ខ្លួនទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ មិនមែនជារបស់ខ្លួន តែញាណ មិនប្រព្រឹត្តទៅថា វិញ្ញាណមិនមែនជារបស់ខ្លួនទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៨) បុគ្គលកាលនិយាយពាក្យថា ឥទំ ទុក្ខំ (នេះជាទុក្ខ) ញាណ ប្រព្រឹត្តទៅថា ឥទំ ទុក្ខំ (នេះជាទុក្ខ) ដែរឬ ។ អើ ។ ញាណ ប្រព្រឹត្តទៅថា ឥ ផង ថា ទំ ផង ថា ទុ ផង ថា ខំ ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ឥទំ ទុក្ខកថា ។

# ឥទ្ធិពលកថា

(២៩) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ឥទ្ធិមយិកោ សោ អាយុ ឥទ្ធិមយិកា សា គតិ ឥទ្ធិមយិកោ សោ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ អតីតំ កប្បំ តិដ្ឋេយ្យ អនាគតំ កប្បំ តិដ្ឋេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ទ្វេ កប្បេ តិដ្ឋេយ្យ តយោ កប្បេ តិដ្ឋេយ្យ ចត្តារោ កប្បេ តិដ្ឋេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ ប ។ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ សតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យ អសតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យាតិ ។ សតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យាតិ ។ ហញ្ចិ សតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យ នោ វត រេ វត្តព្វេ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ បេ ។ អសតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យាតិ ។ មរតោ តិដ្ឋេយ្យ កាលកតោ តិដ្ឋេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# ឥទ្ធិពលកថា

(២៩) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្ប (មហាកប្ប) ឬ ។ អើ ។ អាយុដែលសម្រេចដោយឫទ្ធិនោះ គតិដែលសម្រេចដោយឫទ្ធិនោះ ការបាននូវអត្តភាពដែលសម្រេចដោយឫទ្ធិនោះ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គល គប្បីឋិតនៅអស់កប្បជាអតីត គប្បីឋិតនៅអស់កប្បជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយកំម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គល គប្បីឋិតនៅអស់ ២ កប្ប គប្បីឋិតនៅអស់ ៣ កប្ប គប្បីឋិតនៅអស់ ៤ កប្បដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គល កាលបើជីវិតមាននៅ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ កាលបើជីវិតមិនមានទេ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ។ បុគ្គលកាលបើជីវិតមាន គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ។ ប្រសិនបើ បុគ្គល កាលបើជីវិតមាននៅ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្របកដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បទេ ។ បេ ។ បុគ្គល កាលបើជីវិតមិនមានទេ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ។ មានតែបុគ្គលស្លាប់ហើយ គប្បីឋិតនៅ បុគ្គល មានមរណកាលធ្វើហើយ គប្បីឋិតនៅដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣០) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ឧប្បន្នោ ផស្សោ មា និរុជ្ឈីតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឧប្បន្នា វេទនា ។ បេ ។ ឧប្បន្នា សញ្ញា ។ បេ ។ ឧប្បន្នា ចេតនា ។ បេ ។ ឧប្បន្នំ ចិត្តំ ឧប្បន្នា សទ្ធា ឧប្បន្នំ វីរិយំ ឧប្បន្នា សតិ ឧប្បន្នោ សមាធិ ។ បេ ។ ឧប្បន្នា បញ្ញា មា និរុជ្ឈីតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ រូបំ និច្ចំ ហោតូតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ និច្ចំ ហោតូតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។

(៣០) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បដែរ ឬ ។ អើ ។ ផស្សៈកើតឡើងហើយ បុគ្គល គប្បីបាន ដើម្បីផ្គង់ឡើង ដោយឫទ្ធិថា កុំរលត់ទៅវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនាកើតឡើងហើយ ។ បេ ។ សញ្ញាកើតឡើងហើយ ។ បេ ។ ចេតនាកើតឡើងហើយ ។ បេ ។ ចិត្តកើតឡើងហើយ សទ្ធាកើតឡើងហើយ វីរិយៈកើតឡើងហើយ សតិកើតឡើងហើយ សមាធិកើតឡើងហើយ ។ បេ ។ បញ្ញាកើតឡើងហើយ បុគ្គល គប្បីបាន ដើម្បីផ្គង់ឡើង ដោយឫទ្ធិថា កុំរលត់ទៅវិញឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ រូប បុគ្គលគប្បីបាន ដើម្បីផ្គង់ឡើង ដោយឫទ្ធិថា ចូរទៀងចុះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ បុគ្គលគប្បីបាន ដើម្បីផ្គង់ឡើង ដោយឫទ្ធិថា ចូរទៀងចុះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣២) បុគ្គលប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បដែរឬ ។

អាមន្តា ។ ជាតិធម្មា សត្តា មា ជាយិំសូតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ជរាធម្មា សត្តា មា ជីរិំសូតិ ។ បេ ។ ព្យាធិធម្មា សត្តា មា ព្យាធិយិំសូតិ ។ បេ ។ មរណធម្មា សត្តា មា មិយ្យិំសូតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣) ន វត្តព្វំ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។

(៣៤) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចតុន្នំ ភិក្ខវេ ធម្មានំ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា

ឥទ្ធិពលកថា

អើ ។ ពួកសត្វមានកិរិយាកើតជាធម្មតា បុគ្គលគប្បីបាន ដើម្បីផ្គងឡើង ដោយឫទ្ធិថា កុំកើតឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វមានសេចក្ដីគ្រាំគ្រាជាធម្មតាថា កុំគ្រាំគ្រាទៅឡើយ ។ បេ ។ ពួកសត្វមានសេចក្ដីឈឺថ្កាត់ជាធម្មតាថា កុំឈឺថ្កាត់ឡើយ ។ បេ ។ ពួកសត្វមានសេចក្ដីស្លាប់ជាធម្មតា បុគ្គលគប្បីបាន ដើម្បីផ្គងឡើងដោយឫទ្ធិថា កុំស្លាប់ឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣) បុគ្គលមិនគួរនិយាយថា បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ឥទ្ធិបាទទាំង៤ បុគ្គលណាមួយ បានបម្រើន បានធ្វើឲ្យច្រើន បានឲ្យប្រព្រឹត្តទៅ បានធ្វើឲ្យជាទីតាំង បានផ្គងឡើង បានសន្សំ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ កាលប្រាថ្នា គប្បីឋិតនៅអស់ ១កប្ប ឬ អស់កប្បដ៏សេសសល់បាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល ដែលប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បបាន ។

(៣៤) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមានបុគ្គលនីមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី

ព្រហ្មា វា កោចិ វា លោកស្មឹ ។ កតមេសំ ចតុន្នំ ។ ជរាធម្មា មា ជីរីតិ នត្ថិ កោចិ អាធិ-ការោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ព្យាធិ-ធម្មា មា ព្យាធិយីតិ ។ បេ ។ មរណធម្មា មា មិយ្យីតិ ។ បេ ។ យានិ ខោ បន តានិ បុព្វេ កតានិ បាបកានិ កម្មានិ សង្កិលេសិកានិ បោ-នោព្ភវិកានិ ទុក្ខុទ្រយានិ ទុក្ខវិបាកានិ អាយតឹ ជាតិជរាមរណិយានិ តេសំ វិបាកោ មា និព្វត្តីតិ នត្ថិ កោចិ អាធិការោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ធម្មានំ នត្ថិ កោចិ អាធិការោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មិន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។

ឥទ្ធិពលកថា ។

ព្រហ្មក្តី ឬក៏ បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានា ដល់ធម៌ទាំង ៤ បានឡើយ ។ ធម៌ទាំង ៤ តើដូចម្តេច ។ មិនមានបុគ្គលណានីមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬក៏ បុគ្គលឯណាមួយក្នុងលោក ជាអ្នកធានាថា សភាវៈមានសេចក្តីគ្រាំគ្រាជាធម្មតា កុំគ្រាំគ្រាឡើយ សភាវៈមានសេចក្តីឈឺថ្កាត់ជាធម្មតា កុំឈឺថ្កាត់ឡើយ ។ បេ ។ សភាវៈមានសេចក្តីស្លាប់ជាធម្មតា កុំស្លាប់ឡើយ ។ បេ ។ កម្មដ៏លាមកទាំងឡាយឯណា ដែលបុគ្គលធ្វើហើយក្នុងកាលមុន ជាកម្មប្រកបដោយសេចក្តីសៅហ្មង អាចធ្វើឲ្យទៅកើតក្នុងភពថ្មីទៀត មានទុក្ខជាកម្រៃ មានវិបាកជាទុក្ខ មានជាតិជរាមរណៈតទៅ មិនមាន បុគ្គលណានីមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬក៏ បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានាថា វិបាករបស់បាបកម្មទាំងនោះ កុំកើតបានឡើយ ម្នាលភិក្ខុទាំងឡាយ មិនមានបុគ្គលណានីមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬក៏ បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានា ដល់ធម៌ទាំង៤នេះឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឡើយ ។

ចប់ ឥទ្ធិពលកថា ។

# សមាធិកថា

(៣៥) ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ អតីតា ចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ អនាគតា ចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ ននុ អតីតំ និរុទ្ធំ អនាគតំ អជាតន្តិ ។ អាមន្តា ។ ហញ្ចិ អតីតំ និរុទ្ធំ អនាគតំ អជាតំ នោ ច វត រេ វត្តព្វេ ចិត្តសន្តតិ សមាធីតិ ។

(៣៦) ឯកចិត្តក្ខណិកោ សមាធីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គី សមាបន្នោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សោតវិញ្ញាណសមង្គី ។បេ។ ឃានវិញ្ញាណសមង្គី ។បេ។ ជិវ្ហាវិញ្ញាណសមង្គី ។បេ។ កាយវិញ្ញាណសមង្គី ។បេ។ អកុសលចិត្តសមង្គី ។បេ។ រាគសហគតចិត្តសមង្គី ។បេ។ ទោសសហគតចិត្តសមង្គី ។បេ។ មោហសហគតចិត្តសមង្គី ។បេ។ អនោត្តប្បសហគតចិត្តសមង្គី សមាបន្នោតិ ។ ន ហេវំ វត្តព្វេ ។បេ។

# សមាធិកថា

(៣៥) តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃចិត្ត ជាអតីត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃចិត្ត ជាអនាគត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ ក្រែងអតីតរលត់ហើយ អនាគតមិនទាន់កើតទេឬ ។ អើ ។ ប្រសិនបើ អតីតរលត់ហើយ អនាគតមិនទាន់កើតទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា តំណនៃចិត្ត ជាសមាធិទេ ។

(៣៦) សមាធិ ប្រកបដោយខណៈនៃចិត្តមួយឬ ។ អើ ។ បុគ្គល ប្រកបដោយចក្ខុវិញ្ញាណ ចូលកាន់សមាបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយសោតវិញ្ញាណ ។ បេ ។ ប្រកបដោយឃានវិញ្ញាណ ។ បេ ។ ប្រកបដោយជិវ្ហាវិញ្ញាណ ។ បេ ។ ប្រកបដោយកាយវិញ្ញាណ ។ បេ ។ ប្រកបដោយអកុសលចិត្ត ។ បេ ។ ប្រកបដោយរាគសហគតចិត្ត ។ បេ ។ ប្រកបដោយទោសសហគតចិត្ត ។ បេ ។ ប្រកបដោយមោហសហគតចិត្ត ។ បេ ។ ប្រកបដោយអនោត្តប្បសហគតចិត្ត ចូលកាន់សមាបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧) ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ អកុ-
សលចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
រាគសហគតា ។ បេ ។ ទោសសហគតា ។ បេ ។
មោហសហគតា ។ បេ ។ អនោត្តប្បសហគតា ចិត្ត-
សន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨) ន វត្តព្វំ ចិត្តសន្តតិ សមាធីតិ ។ អា-
មន្តា ។ ននុ វុត្តំ ភគវតា អហំ ខោ អាវុសោ និ-
គណ្ឋា បហោមិ អនិញ្ជមានោ កាយេន អភាស-
មានោ វាចំ សត្តរត្តិន្ទិវានិ ឯកន្តសុខប្បដិសំវេទី
វិហរិតុន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន
ហិ ចិត្តសន្តតិ សមាធីតិ ។

សមាធិកថា ។

# ធម្មដ្ឋិតតាកថា

(៣៩) ធម្មដ្ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។
តាយ ឋិតតា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។

(៣៧) តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃអកុសលចិត្ត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តំណនៃចិត្ត ដែលប្រកបដោយរាគៈ ។បេ។ ប្រកបដោយទោសៈ ។បេ។ ប្រកបដោយមោហៈ ។បេ។ ប្រកបដោយអនោត្តប្បៈ ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៨) បុគ្គលមិនគួរនិយាយថា តំណនៃចិត្ត ជាសមាធិទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ តថាគត មិនញាប់ញ័រដោយកាយ មិនពោលវាចា អាចដើម្បីនៅជាអ្នកទទួលសេចក្តីសុខតែម៉្យាង អស់យប់និងថ្ងៃទាំងឡាយ៧ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ តំណនៃចិត្ត ជាសមាធិ ។

ចប់ សមាធិកថា ។

# ធម្មដ្ឋិតតាកថា

(៣៩) ធម្មដ្ឋិតតា (ការតាំងនៅនៃធម៌ គឺបដិច្ចសមុប្បាទ) សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។

តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដូបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០) រូបស្ស ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដូបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនាយ ឋិតតា ។ បេ ។ សញ្ញាយ ឋិតតា ។ បេ ។ សង្ខារានំ ឋិតតា ។ បេ ។ វិញ្ញាណស្ស ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដូបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ធម្មដ្ឋិតតាកថា ។

ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់ធម្មដ្ឋិតតានោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤០) ការតាំងនៅនៃរូប សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់ការតាំងនៅនៃរូបនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការតាំងនៅនៃវេទនា ។ បេ ។ ការតាំងនៅនៃសញ្ញា ។ បេ ។ ការតាំងនៅនៃសង្ខារ ។ បេ ។ ការតាំងនៅនៃវិញ្ញាណ សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់ការតាំងនៅនៃវិញ្ញាណនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ធម្មដ្ឋិតតាកថា ។

# អនិច្ចតាកថា

(៤១) អនិច្ចតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ អនិច្ចតាយ អនិច្ចតា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ អនិច្ចតាយ អនិច្ចតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤២) ជរា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ ជរាយ ជរា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ ជរាយ ជរា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៣) មរណំ បរិនិប្ផន្នន្តិ ។ អាមន្តា ។ តស្ស មរណស្ស មរណំ បរិនិប្ផន្នន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តស្ស មរណស្ស មរណំ បរិនិប្ផន្នន្តិ ។ អាមន្តា ។ តស្ស តស្សេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អនិប្ផន្នកថា

(៤១) សេចក្ដីមិនទៀង សម្រេចហើយឬ ។ អើ ។ សេចក្ដីមិនទៀង នៃសេចក្ដីមិនទៀងនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្ដីមិនទៀង នៃសេចក្ដីមិនទៀងនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់សេចក្ដីមិនទៀងនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤២) ផល សម្រេចហើយឬ ។ អើ ។ ផល នៃផលនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ផល នៃផលនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់ផលនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៣) មរណៈ សម្រេចហើយឬ ។ អើ ។ មរណៈ នៃមរណៈនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មរណៈ នៃមរណៈនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្ដិលផ្ដាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់មរណៈនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## អនិច្ចតាកថា

(៦៦) រូបំ បរិជិណ្ណំ រូបស្ស អនិច្ចតា អត្ថីតិ ។ អាមន្តា ។ អនិច្ចតា បរិជិណ្ណា អនិច្ចតាយ អនិច្ចតា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ បរិជិណ្ណំ រូបស្ស ជរា អត្ថីតិ ។ អាមន្តា ។ ជរា បរិជិណ្ណា ជរាយ ជរា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ បរិជិណ្ណំ រូបស្ស ភេទោ អត្ថិ អន្តរធានំ អត្ថីតិ ។ អាមន្តា ។ មរណំ បរិជិណ្ណំ មរណស្ស ភេទោ អត្ថិ អន្តរធានំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ បរិជិណ្ណំ វិញ្ញាណស្ស អនិច្ចតា អត្ថីតិ ។ អាមន្តា ។ អនិច្ចតា បរិជិណ្ណា អនិច្ចតាយ អនិច្ចតា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណំ បរិជិណ្ណំ វិញ្ញាណស្ស ជរា អត្ថីតិ ។ អាមន្តា ។ ជរា បរិជិណ្ណា ជរាយ ជរា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណំ បរិជិណ្ណំ វិញ្ញាណស្ស ភេទោ អត្ថិ អន្តរធានំ អត្ថីតិ ។ អាមន្តា ។

អនិច្ចតាកថា

(៦៦) រូប សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃរូប មានដែរឬ ។ អើ ។ សេចក្ដីមិនទៀង សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃសេចក្ដីមិនទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប សម្រេចហើយ ចុះជរា នៃរូប មានដែរឬ ។ អើ ។ ជរា សម្រេចហើយ ចុះជរា នៃជរា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្ដីអន្តរធាន នៃរូប មានដែរឬ ។ អើ ។ មរណៈ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្ដីអន្តរធាន នៃមរណៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ ពួកសង្ខារ ។ បេ ។ វិញ្ញាណ សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃវិញ្ញាណ មានដែរឬ ។ អើ ។ សេចក្ដីមិនទៀង សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃសេចក្ដីមិនទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណ សម្រេចហើយ ចុះជរា នៃវិញ្ញាណ មានដែរឬ ។ អើ ។ ជរា សម្រេចហើយ ចុះជរា នៃជរា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្ដីអន្តរធាន នៃវិញ្ញាណ មានដែរឬ ។ អើ ។

មរណំ បរិច្ឆិន្នំ មរណស្ស កាលោ អត្ថិ អន្តរធានំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អនិច្ចតាកថា ។

ឯកាទសមោ វគ្គោ ។

## តស្សុទ្ទានំ

អនុសយា អព្យាកតា អហេតុកា ចិត្តវិប្បយុត្តា អញ្ញាណោ វិគតេ ញាណី ញាណំ ចិត្តវិប្បយុត្តំ យត្ថ សច្ចេ ញាណំ បវត្តតិ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យ ចិត្តសន្តតិ សមាធិ ធម្មដ្ឋិតតា អនិច្ចតាតិ ។

មរណៈ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្តីអន្តរធាន នៃមរណៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អនិច្ចតាកថា ។

ចប់ ឯកាទសមវគ្គ ។

## ឧទ្ទាននៃឯកាទសមវគ្គនោះ គឺ

អនុស័យ ជាអព្យាក្រឹត ជាអហេតុកៈ ប្រាសចាកចិត្ត ១ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ បុគ្គលមានញាណ ១ ញាណ ប្រាសចាកចិត្ត ១ ញាណ ប្រប្រព្រឹត្តទៅក្នុងស័ព្ទណា ១ បុគ្គល ប្រកបដោយកម្លាំងនៃឫទ្ធិ គប្បីឋិតនៅអស់កប្ប ១ តំណនៃចិត្ត ជាសមាធិ ១ ធម្មដ្ឋិតតា ១ និងអនិច្ចតា ១ ។

# សំវរោ កម្មន្តិកថា

(៤៥) សំវរោ កម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតិន្ទ្រិយសំវរោ ។ បេ ។ ឃានិន្ទ្រិយសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយសំវរោ ។ បេ ។ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ។ អាមន្តា ។ សោតិន្ទ្រិយសំវរោ ។ បេ ។ ឃានិន្ទ្រិយសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយសំវរោ ជិវ្ហាកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយសំវរោ មនោកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយសំវរោ មនោកម្មន្តិ ។ អាមន្តោ ។ ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយសំវរោ មនោកម្មន្តិ ។ អាមន្តា ។ សោតិន្ទ្រិយសំវរោ ។ បេ ។ ឃានិន្ទ្រិយសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយសំវរោ ។ បេ ។ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# សំវរកម្មន្តិកថា

(៤៩) ការសង្រួម ជាកម្មឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមសោតិន្ទ្រិយ ។ បេ ។ ការសង្រួមឃានិន្ទ្រិយ ។ បេ ។ ការសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អើ ។ ការសង្រួមសោតិន្ទ្រិយ ។ បេ ។ ការសង្រួមឃានិន្ទ្រិយ ។ បេ ។ ការសង្រួមជិវ្ហិន្ទ្រិយ ជាជិវ្ហាកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការសង្រួមសោតិន្ទ្រិយ ។ បេ ។ ការសង្រួមឃានិន្ទ្រិយ ។ បេ ។ ការសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦] អសំវរោ កម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយអសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតិន្ទ្រិយអសំវរោ ។ បេ ។ ឃានិន្ទ្រិយអសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយអសំវរោ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយអសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ អាមន្តា ។ សោតិន្ទ្រិយអសំវរោ ។ បេ ។ ឃានិន្ទ្រិយអសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយអសំវរោ ជិវ្ហាកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយអសំវរោ មនោកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយអសំវរោ មនោកម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយអសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយអសំវរោ មនោកម្មន្តិ ។ អាមន្តា ។ សោតិន្ទ្រិយអសំវរោ ។ បេ ។ ឃានិន្ទ្រិយអសំវរោ ។ ប ។ ជិវ្ហិន្ទ្រិយអសំវរោ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦) ការមិនសង្រួម ជាកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមសោតិន្ទ្រិយ ។ បេ ។ ការមិនសង្រួមឃានិន្ទ្រិយ ។ បេ ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អើ ។ ការមិនសង្រួមសោតិន្ទ្រិយ ។ បេ ។ ការមិនសង្រួមឃានិន្ទ្រិយ ។ បេ ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ជាជិវ្ហាកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការមិនសង្រួមសោតិន្ទ្រិយ ។ បេ ។ ការមិនសង្រួមឃានិន្ទ្រិយ ។ បេ ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៧) ន វត្តព្វំ សំវរោបិ អសំវរោបិ កម្មន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ ។ បេ ។ ន និមិត្តគ្គាហី ហោតិ សោតេន សទ្ទំ សុត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី ហោតិ ។ បេ ។ ន និមិត្តគ្គាហី ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សំវរោបិ អសំវរោបិ កម្មន្តិ ។

**សំវរោ កម្មន្តិកថា ។**

## កម្មកថា

(៤៨) សព្វំ កម្មំ សវិបាកន្តិ ។ អាមន្តា ។ សព្វា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ សវិបាកាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ កិរិយាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ កាមាវចរ វិបាកាព្យាកតា ចេតនា សវិបាកាតិ ។

